# កម្ពុជសុរិយា

# ធម៌ពុទ្ធជ័យមង្គល

## ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

*ប្រែពីបាលី ហើយចងជាពាក្យកាព្យ*

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧២

គ. ស. ១៩២៦

# ធម៌ពុទ្ធជ័យមង្គល[១]

ពីឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ប្រែចេញពីបាលី ហើយចងជាពាក្យកាព្យ

ព្រះគ្រូសំសត្ថា ជួន-ណាត គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ និងព្រះគ្រូ

វិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យក្នុងព្រះរាជបណ្ណាល័យកម្ពុជា

បានផ្ទៀងផ្ទាត់កែសម្រួលត្រឹមត្រូវឡើង

## ពុទ្ធជ័យមង្គល

១. ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ គ្រីមេខលំ
ឧទិតឃោរសសេន មារំ ទានាទិធម្មវិធិនា
ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គ-
លានិ ៗ

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ និម្មិតដៃមួយពាន់ កាន់សស្ត្រាវុធនានា ៗ ជិះគីរីមេខលជាតិ កោញ្ចនាទខ្ទរពេសុធា ព្រមដោយមារសេនា ពន្លឹកលាន់កងស័ព្ទសូរ ៗ ដោយធម្មវិធី ទានបារមីជាប្រធាន ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ៗ វិជ័យ-មង្គល ចូរមានដល់អ្នកកល់គ្នា ដោយតេជៈជ័យា ព្រះឈ្នះមារគ្រោះនោះហោង ៗ

---

១- អត្ថបទនេះ ស្រង់ពីកម្ពុជសុរិយា ក្បាលលេខ ៥ ឆ្នាំ ១៩២៦-២៧ ៗ

២- មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ ឃោរម្បនាឡ-
វកមក្ខមថទ្ធយក្ខំ ខន្តីសុទន្តវិធិនា ជិតវា
មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទ្រពិននាយក ផ្ចាញ់អាឡវកយក្ខឃោរឃៅ រឹងរូសមិនតាំង នៅ ក្នុងខន្តីគុណសភាព ។ ហេតុអស់រាត្រី ព្រះជិនស្រ័ប្រទ័យុទ្ធនា ក្រៃលែង ក្រូរមារ ក្នុងបប់មសម្ពោធិ ។

ដោយព្រះពិធីញាណ ទ្រង់ខ្ចាន់ដោយខន្តី ញុំាងចិត្តអសុរី ឲ្យបង់ព្យសពុះវន្លា ។ វិជ័យមង្គល ចូរមានដល់អ្នកកល់គ្នា ដោយតេជៈជ័យា ព្រះឈ្នះអាឡវយក្ខហោង ។

៣- នាឡាគិរឹ គជវរំ អតិមត្តភូតំ ទាវគ្គិចក្កម-
សនីវ សុទារុណន្តំ មេត្តម្ពុសេកវិធិនា ជិតវា
មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទ្រពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា គិរីវេគជា ដំហានក្លាពុះប្រេងព្រោច ។ សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកាំអសនី ។ ដោយព្រះពិធីស្រប ស្រោចទឹកអប់គឺបារមី មេត្តាព្រះជិនស្រី ញុំាងដំរីឲ្យជ្រះថ្លា ។ វិជយមង្គល ចូរមានដល់អ្នកកល់គ្នា ដោយតេជៈជ័យា ព្រះឈ្នះនាឡាគិរី ។

៤. ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ ធាវន្តិ យោ
ជនបថង្គុលិមាលវន្តំ ឥទ្ធីភិសំខតមនោ ជិតវា
មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ ផ្ចាញ់ចោរអង្គុលិ-មាល មានកម្រងគឺម្រាមដៃ ៗ នៃមនុស្សដែលគាត់កាត់ មកដោតពាក់ជាមាល័យ អង់អាចកំណាចក្រៃ ជំនាញដៃស្ទាត់ប្រហារ ៗ កាន់ដាវដើរគ្រវី ដេញព្រះមុនីសាស្តាចារ្យ ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជន៍ណា ៗ រីជ័យមង្គល ចូរមានដល់អ្នកកល់គ្នា ដោយតេជៈជយា ព្រះឈ្នះអង្គុ-មាល ៗ

៥. កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា ចិញ្ចាយ ទុដ្ឋ-
វចនំ ជនកាយមជ្ឈេ សន្តេន សោមវិធិនា ជិត-
វា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ស្ត្រីពាក្យនាងចិញ្ចា អំពើធ្វើដូចជាស្រីមានគភ៌ពាល់ពើសពោះ ៗ យកឈើធ្វើជាកូន ពន្ធពោះខ្លួនពោល ប្រគេះ ព្រះពុទ្ធឈ្មោះគោតមនោះ ដោយសមាចារពិធី ៗ រម្ងាប់ពាក្យ បណ្តាល នាកណ្តាលជំនុំប្រុសស្រី ចិញ្ចាពញ់បាមី គឺសច្ចំពាក្យសត្យា ៗ រីជ័យមង្គល ចូរមានដល់អ្នកកល់គ្នា ដោយតេជៈជយា ព្រះសាស្តាឈ្នះចិញ្ចា ៗ

៦. សច្ចំ វិហាយមតិសច្ចកវាទកេតុំ វាទាភិរោ-
បិតមនំ អតិអន្ធភូតំ បញ្ញាបទីបជលិតោ ជិតវា
មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាងដោយបញ្ញា ផ្ចាញ់សច្ចកជានិគ្រន្ថៈក្រៅពុទ្ធវិន័យ ។ អញ្ញាស្រ័យលះបង់ពាក្យសត្យត្រង់តាមគាប់ចិត្ត សរសើរខ្លួនឯងថៃ លើកតម្កល់ដូចជង់ទង់ ។ បង្អើតម្ងរងងឹតដោយពោលឥតពាក្យទៀងត្រង់ ព្រះទ្រង់កំចាត់បង់ ដោយប្រទីបគឺបញ្ញា ។ ជ័យមង្គល ចូរមានដល់អ្នកកាល់គ្នា ដោយតេជៈជយា ឈ្នះសច្ចកនិគ្រន្ថ ។

៧ នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធិំ បុត្តេន ថេរភុជ-
គេន ទមាបយន្តោ ឥទ្ធូបទេសវិធិនា ជិតវា មុនិ-
ន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានសំណាច ឲ្យប្លែងជានាគរាជ ទៅទូន្មានភុជង្គ ។ ឈ្មោះនន្ទោបនន្ទចិត្តមោហធ្ងន់រឿង ឫទ្ធិរង្គ ទិដ្ឋិកាចទ្រូទន់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។ គឺឲ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន ឫទ្ធិនាគអន្តរធាន ទុនបុះបាញ់ព្រះបស្កា ។ ជ័យមង្គល ចូរមានដល់អ្នកកាល់គ្នា ដោយតេជៈជយោ ព្រះភគវាឈ្នះនាគបោរាណ ។

៨. ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ ព្រហ្មំ វិសុទ្ធិ-
ជុតិមិទ្ធិពកាភិធានំ ញាណាគទេន វិធិនា ជិ-
តវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទព្រះគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា សម្គាល់ថាអាត្មា វិសេសវៀសដោយគុណវិសុទ្ធិ ។ ដែលកាន់អាសិរពិស គឺចិត្តទ្រឹស្ដិដ៏មួយមុត កាន់ខុសផ្លូវសម្ទុះ មិនលើកលាកលះបង់ព្រួណា ។ ទ្រង់ឈ្នះដោយពិធី នុសចារិសេសសម្រាន្ត ជំត្រូវតាមសន្តាន គឺព្រះញាណប្រោសទេសនា ។ វិជ័យមង្គល ចូរមានដល់អ្នកកល់ត្នា ដោយតេជៈដយា ឈ្នះព្រហ្មាឥត មានហ្មង ។

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា យោ វាចនោ-
ទិនទិនេ សរតេ មតន្ទី ហិត្វាននេកវិវិធានិ ចុបទ្ទ-
វានិ មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។

យោនរៈជនឯណា កបបញ្ញាប្រាសក្ដិខិល ខុះឃ្លាត់សាដ៏ខាន សឹល សូត្រនៃ្ទកព្រះធម៌ថ្ងៃ ។ គឺជាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ ទំសូត្រសព្វៗថ្ងៃ កើតមង្គលជានិរន្តរ៍ ។ នោះនរជននោះ បានដោះ ពេកតាសន្ធ ឧបទ្រពអនេកលន់ មានប្រការផ្សេងៗផង ។ ទីនដល់ធម៌ កេស្រមក្សាន្ត គឺព្រះនិព្វានសុខកន្លង់ លែងទុក្ខទាំង ៤ ករ ដោយពុទ្ធជ័យ មង្គលនេះ ។

ចប់ពុទ្ធជយមង្គលប្រែតែប៉ុណ្ណេះ